ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ១១ សណន

ស

# សេចក្តីណែនាំ

## ស្តីពី

## ការកសាងឯកសារចុះបញ្ជីដីធ្លី

មុននឹងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្រសួងបានចេញឯកសារបណ្តុះបណ្តាលជំនាន់ទី១ នាខែ មករា ឆ្នាំ២០០៣ និងជំនាន់ទី២ នាខែមីនា ឆ្នាំ ២០០៤ និងបានដំណើរការបណ្តុះបណ្តាលមន្ត្រីជំនាញទាំងអស់ អំពីនីតិវិធីនៃការបំពេញទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី តែក្នុងការអនុវត្តន៍ជាក់ស្តែង ក្រសួងបានពិនិត្យឃើញថាការកសាងឯកសារចុះបញ្ជីដីធ្លីនៅតាមខេត្ត-ក្រុងអនុវត្តគំរោងមួយចំនួនមានការធ្វេសប្រហែស ខ្វះការទទួលខុសត្រូវ ទាំងនីតិវិធី និងទិដ្ឋភាពគតិយុត្ត ពិសេសទាក់ទងនឹងការកំណត់អត្តសញ្ញាណម្ចាស់អចលនវត្ថុ ។

ដើម្បីចៀសវាងកំហុសឆ្គង និងបាតុភាពខាងលើ ក្រសួងធ្វើការណែនាំ ដូចខាងក្រោម :

១-មន្ត្រីវិនិច្ឆ័យ ត្រូវផ្អែកលើច្បាប់ និងបទដ្ឋានគតិយុត្តដែលមានជាធរមានក្នុង ការកំណត់អត្តសញ្ញាណម្ចាស់អចលនវត្ថុជាអាទិ៍ : ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែង កំណើត សញ្ជាតិ សាវតា និងស្ថានភាពស៊ីវិល នៅពេលបំពេញទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

២-មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ និងទទួលខុសត្រូវ រាល់ទិន្នន័យនៅក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

៣- មន្ត្រីបញ្ចូលទិន្នន័យ (GIS) ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ ។ ទិន្នន័យដែលបញ្ចូលក្នុងកុំព្យូទ័រ ត្រូវតែធានាត្រឹមត្រូវ ។ មន្ត្រីទទួលបន្ទុកមិនត្រូវកែប្រែ ឬបន្ថែមឱ្យខុសពីទិន្នន័យនៃទំរង់បែបបទ តាមទំនើងចិត្តឡើយ ពុំនោះនឹងត្រូវប្រឈមនឹងច្បាប់ និងបទបញ្ជាជាធរមាន។



អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659 - 215 660 , Fax : (855) 023 215 277, e-mail : im. c . lim. @ Camnet. Com. kh

៤-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រុង ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកត្រួតពិនិត្យគុណភាព ។ មន្ត្រីទទួលបន្ទុកនេះ ត្រូវផ្សេងពីមន្ត្រីបញ្ចូលទិន្នន័យ ។

( ភ្ជាប់ជាមួយឯកសារឧបសម្ព័ន្ធណែនាំស្តីពីការកសាងឯកសារចុះបញ្ជីដីធ្លី )

ទទួលបានសេចក្តីណែនាំនេះ គ្រប់មន្ទីរអនុវត្តគំរោងទាំងអស់ត្រូវចាត់ចែងអនុវត្ត ខ្លឹមសារខាងលើអោយមានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦

ជ.នាយករដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ឆាន់_សាផាន

<u>ចម្លងជូន:</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលាខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ